# San Diego Unified School District

EUGENE BRUCKER EDUCATION CENTER
4100 Normal Street, San Diego, CA 92103-2682


William A. Kowba
អ្នកតំណាងអគ្គស្នងការក្រសួងអប់រំ

ថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០០៨

មាតាបិតា/អ្នកអាណាព្យាបាលសិស្សជាទីរាប់អាន:

ពេលនេះ យើងចាប់ផ្តើមរៀបចំបង្កើតថវិការសំរាប់ប្រើប្រាស់ឆ្នាំសិក្សា ២០០៨-០៩ នេះ ហើយយើងកំពុងតែប្រឈរទប់ទល់នឹងបញ្ហាមួយចំនួនទាពេលខាងមុខនេះ។ បញ្ហាស្តីអំពី ថវិការដែលយើងទាំងអស់គ្នានឹងត្រូវការដោះស្រាយ - មាតាបិតា, បុគ្គលិកសាលារៀន, សមាជិកគណៈកម្មការអប់រំ ព្រមទាំងសមាជិកសហគមន៍ - ដូច្នេះ យើងបន្តការដោះស្រាយបានប្រសើរដើម្បីជាផលប្រយោជន៍ដ៏ប្រសើរសំរាប់ការសិក្សា និងសាលារៀនរបស់យើង។

យើងទាំងអស់ភាគច្រើនបានឃើញពត៌មានចេញផ្សាយអំពី " ឆ្នាំដែលមានភាពអាសន្ន "ដែលមានការជាប់ទាក់ទងនឹងរដ្ឋ California ។ លោកចៅហ្វាយខែត្រ Schwarzenegger បានដាក់ការស្នើរសុំកាត់បន្ថយថវិការសំរាប់កិច្ចការបំរើទូទៅ និងកម្មវិធីបំរើក្នុងរដ្ឋ, រួមនឹងការកាត់បន្ថយថវិការរាប់រយលានដុល្លារចំពោះការអប់រំនាឆ្នាំនេះ, ព្រមទាំងការកាត់បន្ថយថវិការចំនួន ៤.៤កោដិដុល្លារ សំរាប់ឆ្នាំខាងមុខនេះ។ ក្រសួងអប់រំប្រចាំក្រុងក្នុងរដ្ឋ California ទាំងអស់បានរួបរួមគ្នាដើម្បីស្វែងរកមធ្យោបាយដើម្បីដោះស្រាយបញ្ហានេះដើម្បីកុំអោយមានកបញ្ហាទៅលើលោកគ្រូ-អ្នកគ្រូបំរើនៅតាមសាលារៀន និងសិស្សសិក្សា។

បញ្ហាថវិការទាំងនេះបានដាក់សំពាតទៅលើការអប់រំរបស់យើងសំរាប់ឆ្នាំ ២០០៨-០៩ ដែលមានរួមនឹងចំណុចសំខាន់ដូចជា:

- គោលការកាត់បន្ថយដែលចេញពីលោកចៅហ្វាងខែត្រ
- ថវិការកម្មវិធី Title I និងថវិការសហព័នផ្សេងត្រូវបានកាត់បន្ថយ
- ការកាត់បន្ថយថវិការរដ្ឋសំរាប់កម្មវិធីអប់រំ " ផ្នែកណាមួយ"
- មាន " ច្បាប់ " ថ្មី សំរាប់ការប្រើប្រាស់ថវិការ "ផ្នែកណាមួយ "
- ការចំណាយទៅលើសាលារៀនការកើនឡើងជាលំដាប់
- ការក្សាប្រាក់ខែបុគ្គលិកការងារអោយមានស្ថេរភាព
- ការចំណាយទៅលើផ្នែក សុខភាព និងសុខមារភាពបុគ្គលិកការងារ កើនឡើងជាលំដាប់

កិច្ចការប្រជុំជាដំបូងបានបញ្ជាក់ថា យើងអាចបន្ថយការចំណាយប្រមាណ ៧០លានដុល្លារ។ យើងបានធ្វើការកែប្រែកិច្ចការទូទៅនៅតាមការិយាល័យមជ្ឈមណ្ឌលអប់រំក្នុងការកាត់បន្ថយការចំណាយជាច្រើន។ បន្ថែម នៅតាមការិយាល័យផ្នែកនិមួយៗរបស់មជ្ឈមណ្ឌលអប់រំរបស់យើងបានកំរិតកាត់បន្ថយចំនួ ១០-១៥ភាគរយ។ យើងកំពុតែរកមធ្យោបាយកាត់បន្ថយកម្មវិធីដែលមិនធ្វើអោយប៉ះពាល់ដល់សិស្សរបស់យើង។

ទំហំនៃការកាត់បន្ថយនេះនឹងធ្វើឡើងលើសពីមជ្ឈមណ្ឌលអប់រំ។ យើងសុំអោយបុគ្គលិកការងារ និងលោកអ្នក, មាតាបិតារបស់យើងជួយផ្តល់នូវយោបល់-មតិស្តីអំពីការកាត់បន្ថយថវិការ និងបង្កើនថវិការ។ យើងស្វាគមន៍យោបល់-មតិទាំងអស់ ហើយនឹងយកមកធ្វើការពិចារណា។ ពត៌មានបន្ថែម សូមពិនិត្យមើលប្រព័នវែបសាយរបស់យើង www.sandi.net/budget ។ ទំព័រវែបសាយនេះ មានរួមនឹងពត៌មានស្តីអំពី ការបង្កើតថវិការរបស់ក្រសួងអប់រំ, ការជាប់ទាក់ទងនឹងពេលវេលា និងទីកន្លែងដែលលោកអ្នកផ្តល់ជាយោបល់-មតិបាន។

យើងមានសេចក្តីត្រេតអរ និងត្រូវការជាបន្តនូវកិច្ចគាំទ្ររបស់លោកអ្នកដ៏ប្រុងប្រយ័ត្នក្នុងការគាំទ្រលោកគ្រូ-អ្នកគ្រូ និងសិស្សសិក្សានៅតាមសាលារៀនឲ្យមានជ័យជំនះ។ ខ្ញុំនឹងបន្តការផ្តល់ពត៌មានដល់លោកអ្នកអោយបានជ្រាបអំពី គម្រោងការរៀបចំផ្នែកថវិការរបស់យើង ពេលយើងបានទទួលពត៌មានថ្មីៗពី រដ្ឋ។

សូមអរគុណលោកអ្នកសារជាថ្មីដែលបានព្យាយាមប្រែងប្រែងជួយដោះស្រាយដែលជាផលប្រយោជន៍សំរាប់សិស្សទាំងអស់

ដោយក្តីរាក់ទាក់

William A. Kowba
អ្នកតំណាងអគ្គស្នងក្រសួងអប់រំប្រចាំក្រុង